# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងកម្មវិធីព្រឹត្តិការណ៍សង្គម-វប្បធម៌ នៅទីស្នាក់ការអង្គការពាណិជ្ជកម្មពិភពលោក

## ទីក្រុងហ្សឺណែវ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៩

## (រយៈពេល ១០ នាទី)

- ***ឯកឧត្តម រ៉ូប៊ែតូ អាហ្សេវ៉េដូ*** *(Roberto Azevêdo)* ***អគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក***
- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

ខ្ញុំពិតជាមានសេចក្តីរីករាយជាអនេក ដែលកម្ពុជាត្រូវបានផ្តល់កិត្តិយសដ៏ឧត្តុង្គឧត្តម ឱ្យធ្វើជាម្ចាស់កម្មវិធីសង្គម-វប្បធម៌នេះ ។ ខ្ញុំសូមកោតសរសើរចំពោះលេខាធិការដ្ឋាន WTO ដែលបានសហការជា-មួយក្រសួងពាណិជ្ជកម្ម និងស្ថានបេសកកម្មកម្ពុជាប្រចាំ WTO រៀបចំកម្មវិធីដ៏វិសេសវិសាល នៅទីកន្លែងដ៏ស្រស់ស្អាតនេះ ។ ទន្ទឹមនេះ ខ្ញុំសូមអរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមក្នុងកម្មវិធីជួបជុំនេះ ។

ខ្ញុំពិតជាមានមោទនភាពយ៉ាងខ្លាំង ដែលឯកឧត្តម **រ៉ូប៊ែតូ អាហ្សេវ៉េដូ** បានលើកទឹកចិត្តដល់កម្ពុជាក្នុងជំនួបទ្វេភាគី កាលពីខែ តុលា ឆ្នាំ ២០១៨ និង ក្នុងជំនួបកាលពីព្រឹកមិញនេះ ដោយបានបញ្ជាក់ថា ទោះបីជាស្ថិតក្នុងឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចក្តី តែកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងអាស៊ាន និងក្នុង WTO ជាពិសេស បានធ្វើជាអ្នកសម្របសម្រួលបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៨ ប្រកបដោយជោគជ័យ ។ ជាការពិត ក្នុងនាមជាប្រទេសដែលមានសេដ្ឋកិច្ចតូច កម្ពុជាជឿលើអត្ថប្រយោជន៍នៃសកលភាវូបនីយកម្ម និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឈរលើវិធានគតិយុត្តិ ។ យើងយល់ថា ពាណិជ្ជកម្មពិភពលោកមិនគួរត្រូវបានរាំងស្ទះដោយសារការកំណត់ពន្ធជាឯកតោភាគីនោះទេ ប៉ុន្តែគប្បីត្រូវបានលើកតម្កើង និងគាំទ្រ តាមរយៈការប្រកាន់នូវគោលនយោបាយអំណោយផលសមស្រប ព្រមទាំងការផ្តល់ក្របខ័ណ្ឌអនុគ្រោះពិសេសដល់ប្រទេសកំពុងអភិវឌ្ឍន៍ ។ គឺនៅលើមូលដ្ឋាននៃជំនឿឥតងាករេនេះហើយ ដែលខ្ញុំបានណែនាំដល់រដ្ឋមន្ត្រីពាណិជ្ជកម្ម និងអគ្គរាជទូតរបស់ខ្ញុំ ឱ្យបន្តកិច្ចសហការជាមួយសមាជិកដទៃទៀត ឱ្យមានប្រសិទ្ធភាពបំផុត ក្នុងដំណើរការចរចាកែទម្រង់ WTO នៅក្នុងកាលៈទេសៈបច្ចុប្បន្ន ដែលតម្រូវឱ្យយើងរួមគ្នាពង្រឹងស្ថាប័នសកល **«ពហុភាគីនិយម»** ដ៏មានសារៈសំខាន់មួយនេះ ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

នៅក្នុងប្រវត្តិសាស្ត្រទំនើបរបស់ខ្លួន កម្ពុជាបានជួបប្រទះនឹងគ្រោះមហន្តរាយដ៏ធំមួយ គឺការធ្លាក់ចូលទៅក្នុងសង្គ្រាមឥណ្ឌូចិនក្នុងឆ្នាំ ១៩៧០-១៩៧៥ និងរបបខ្មែរក្រហមក្នុងឆ្នាំ ១៩៧៥-១៩៧៩ ដែលបានបំផ្លាញដល់ឫសគល់នូវហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចរបស់ជាតិ ។ ពួក **ប៉ុល ពត** បានសម្លាប់អ្នកចេះដឹងស្ទើរតែគ្មានសល់ ហើយបានបន្សល់ទុកនៅកម្ពុជាដ៏កំសត់នាពេលនោះ នូវគំនរផេះផង់ និងទឹកភ្នែក ។ ថ្វីត្បិតរបបខ្មែរក្រហមត្រូវបានបញ្ចប់នៅថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ តែសង្គ្រាមស៊ីវិលនៅក្នុងប្រទេសនៅតែបន្តអូសបន្លាយ ។ ស្ថិតនៅក្នុងស្ថានភាព **«មានសង្គ្រាមផង និងសន្តិភាពផង»** កម្ពុជាពេលនោះ បានប្រើប្រាស់ដៃម្ខាងសម្រាប់ការពារប្រទេសពីការវិលត្រឡប់មកវិញនៃអំពើប្រល័យពូជសាសន៍ និងដៃម្ខាងទៀតសម្រាប់កសាង និងអភិវឌ្ឍប្រទេសឡើងវិញពីចំណុចសូន្យ ក្នុងកាលៈទេសៈដែលមានការហ៊ុំព័ទ្ធ និងការដាក់ទណ្ឌកម្មសេដ្ឋកិច្ចពីខាងក្រៅដោយអយុត្តិធម៌ ។ នាពេលនោះ ក្នុងនាមជាអ្នកដឹកនាំកំពូលមួយរូបនៃរដ្ឋាភិបាល ខ្ញុំបានប្រមូលធនធានមនុស្សដែលនៅសេសសល់ពីស្លាប់ ហើយមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រក្នុងចំនួនមិនដល់ ១០០ នាក់ផង មកធ្វើការនៅក្នុងក្រសួង-ស្ថាប័នរបស់រដ្ឋ ដើម្បីរៀបចំស្តារប្រទេស និងជីវភាពប្រជាជនឡើងវិញ ខណៈដែលហេដ្ឋារចនាសម្ព័ន្ធ និងមូលដ្ឋានផលិតកម្មគ្រប់ប្រភេទ ត្រូវបានបំផ្លាញអស់គ្មានសល់ ។ រីឯច្រកពាណិជ្ជកម្ម ក៏អាចធ្វើបានតែជាមួយប្រទេសមួយចំនួនតូចប៉ុណ្ណោះ ។

ទោះបីកម្ពុជាសម្រេចបាននូវសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស នាឆ្នាំ ១៩៩១ និង បានរៀបចំការបោះឆ្នោតលើកទីមួយនៅក្នុងឆ្នាំ ១៩៩៣ សង្គ្រាមស៊ីវិលនៅតែបន្ត ។ លោកអ្នកទាំងអស់គ្នាប្រាកដជាអាចយល់បានយ៉ាងច្បាស់ថា ការកសាងប្រទេសជាតិមិនអាចធ្វើទៅបាននោះទេនៅក្នុងកាលៈទេសៈដែលមានសង្គ្រាមឥតឈប់ឈរ ។ នេះគឺជាហេតុផលដែលជំរុញឱ្យខ្ញុំដាក់ចេញនូវ «**គោលនយោបាយឈ្នះ-ឈ្នះ**» ដែលបាននាំមកជូនកម្ពុជានូវការបញ្ចប់សង្គ្រាមទាំងស្រុង និងការទទួលបាននូវសុខសន្តិភាព ការបង្រួបបង្រួមជាតិ និងឯកភាពជាតិពេញលេញនៅក្នុងទូទាំងប្រទេសជាលើកដំបូង នៅចុងឆ្នាំ ១៩៩៨ ក្នុងប្រវត្តិសាស្ត្រកម្ពុជាច្រើនទសវត្សរ៍ចុងក្រោយនេះ ។ ដូចខ្ញុំធ្លាប់បានគូសបញ្ជាក់ នេះគឺជាសន្តិភាពដែលសម្រេចបានមកដោយកម្ពុជាខ្លួនឯងផ្ទាល់ ដោយគ្មានការបង្ហូរឈាម គ្មានការប្រើអាវុធ ឬ គ្រាប់រំសេវ សូម្បីតែមួយគ្រាប់ និងដោយគ្មានការបង្គាប់បញ្ជា ឬ ការជួយជ្រោមជ្រែងពីខាងក្រៅ ។

លើមូលដ្ឋាននៃសុខសន្តិភាពដែលសម្រេចបានមកដោយលំបាកលំបិននេះ តពី **យុទ្ធសាស្ត្រត្រី-កោណ** ដែលត្រូវបានដាក់ចេញតាំងពីចុងឆ្នាំ ១៩៩៨ មក ខ្ញុំបានដាក់ចេញនូវ **យុទ្ធសាស្ត្រចតុកោណ** នៅឆ្នាំ ២០០៣ ដែលបានដើរតួជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សម្រាប់អនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។ នៅក្នុងចំណោមកិច្ចការសំខាន់ៗដែលជារបៀបវារៈគោលនយោបាយសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា **យុទ្ធសាស្ត្រចតុកោណ** ក៏បានកំណត់យកការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ជាអាទិភាពដ៏សំខាន់មួយផងដែរ ។ ឆ្លើយតបទៅនឹងយុទ្ធ-

សាស្ត្រនេះ កម្ពុជាបានចាប់ផ្តើមកសាងហេដ្ឋារចនាសម្ព័ន្ធទន់ និងរឹង ធនធានមនុស្ស ច្បាប់ និងបទដ្ឋានគតិយុត្តិនានា ដើម្បីជាមូលដ្ឋានក្នុងការចូលជាសមាជិក WTO រហូតបានក្លាយជាសមាជិកពេញសិទ្ធិនៅខែ តុលា ឆ្នាំ ២០០៤ ។

## *ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

ខ្ញុំពិតជាមានមោទនភាព ក្នុងការជម្រាបជូនដល់អស់លោកអ្នកទាំងអស់គ្នាថា ជាលទ្ធផលនៃការ-ពុះពារ និងការប្រឹងប្រែងដើម្បីរស់ឡើងវិញ ស្តារ កសាង និងអភិវឌ្ឍជាតិក្នុងរយៈពេល ៤០ ឆ្នាំចុងក្រោយនេះ កម្ពុជាសម្រេចបាននូវការក្រៃប្រែមុខមាត់ដែលគ្មានអ្នកណាអាចនឹកស្មានដល់ ។ ពេលនេះ ប្រជាជាតិកម្ពុជាកំពុងតែសប្បាយរីករាយទទួលផលពីសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រសម័យទំនើបរបស់ខ្លួន ។ កម្ពុជា គឺជាករណីជោគជ័យសំខាន់មួយរបស់ប្រទេសដែលធ្លាប់ត្រូវបានញាំញីដោយសង្គ្រាម ហើយសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈ ។

ពីប្រទេសដែលល្បីក្នុងការប្រើអាវុធ ដើម្បីដណ្តើមអំណាចគ្នា និងក្នុងការផ្លាស់ប្តូររដ្ឋាភិបាល ឥឡូវនេះ កម្ពុជាបានក្លាយជាប្រទេសដែលគ្រប់គ្រងដោយនីតិរដ្ឋ ហើយគោរពយ៉ាងមុតមាំនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី- ពហុបក្ស ជាមួយនឹងការរៀបចំការបោះឆ្នោតដោយទៀងទាត់ សេរី និងយុត្តិធម៌ ដើម្បីផ្តល់សិទ្ធិឱ្យប្រជាជនអាចជ្រើសរើសមេដឹកនាំប្រទេស ។

ពីប្រទេសមួយដែលធ្លាប់តែត្រូវបានគេស្គាល់ថា ជាវាលពិឃាដ ជាតំបន់អសន្តិសុខ ដោយសារជម្លោះប្រដាប់អាវុធ និងសំណល់គ្រាប់មីនដ៏គ្រោះថ្នាក់ និងជាប្រទេសមានសេដ្ឋកិច្ចអន់ថយ ផុងជាប់ក្នុងភាពក្រីក្រ និងមានអសន្តិសុខស្បៀង កម្ពុជាបច្ចុប្បន្ន ទទួលបានសន្តិភាពពេញលេញ និងបានក្លាយជាគោលដៅទេសចរណ៍ដ៏មានប្រជាប្រិយនៅតំបន់អាស៊ីអគ្នេយ៍ ជាប្រទេសនាំចេញស្បៀងអាហារ មានស្នាដៃលេចធ្លោក្នុងការកាត់បន្ថយភាពក្រីក្រ និងការកែលំអសូចនាករសង្គមនានា និងជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅក្នុងពិភពលោក ដែលថ្មីៗនេះ បានឆ្លងផុតដោយជោគជ័យពីឋានៈជាប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ដោយសារកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ ក្នុងរង្វង់ជាង ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក ព្រមទាំងកំពុងប្រឹងប្រែងដើម្បីក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

សម្រាប់ឆ្នាំ ២០១៨ កន្លងទៅនេះ អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបាន ៧,៥% ជាមួយនឹងការ-ព្យាករណ៍ថា នឹងអាចបន្តរក្សាបានក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលមធ្យមទៅមុខ ។ អត្រានៃភាពក្រីក្របានធ្លាក់ចុះពី ៥៣,២% ក្នុងឆ្នាំ ២០០៤ មកនៅក្រោម ១០% ក្នុងឆ្នាំ ២០១៨ ។ ជាមួយគ្នានេះដែរ កម្ពុជាបានធ្វើពិពិធកម្មជាបណ្តើរៗនូវមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួន ទាំងផលិតផល និងទីផ្សារ ដែលក្នុងនោះការនាំចេញរបស់កម្ពុជាបានកើនពី ៥,៧ ប៊ីលានដុល្លារ (ស្មើនឹង ៤០,៥% នៃ ផសស) នៅឆ្នាំ ២០១២ មក

ដល់ ១៣ ប៊ីលានដុល្លារ (ស្មើនឹង ៥៣,២% នៃ ផសស) នៅឆ្នាំ ២០១៨ និងបានធ្វើពិពិធកម្មបន្តិចម្តងៗ ពីការនាំចេញសម្លៀកបំពាក់ទៅកាន់ផលិតផលផ្សេងទៀត ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

មុននឹងបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដល់បណ្តាប្រទេស និងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានជួយដល់កម្ពុជា និងបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចក្នុងរយៈពេលកន្លងមក ហើយក៏សូមអំពាវនាវដល់សមាជិក WTO និងដៃគូអភិវឌ្ឍន៍ទាំងឡាយ ឱ្យបន្តជួយដល់ប្រទេសសមាជិកក្រីក្រឱ្យបានចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច និងអាចបន្តជំរុញកិច្ចដំណើរការអភិវឌ្ឍន៍របស់ខ្លួនទៅមុខកាន់តែលឿនថែមទៀត ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃអង្គការសហប្រជាជាតិ ។

ខ្ញុំសង្ឃឹមថា កម្មវិធី «**សង្គម-វប្បធម៌**» នេះ នឹងផ្តល់ឱកាសដល់អ្នកចូលរួមទាំងអស់ ពិភាក្សា និងផ្លាស់ប្តូរយោបល់លើគ្រប់បញ្ហាដែលជាឧត្តមប្រយោជន៍នៃប្រទេសយើងនីមួយៗ ។

ជាទីបញ្ចប់ ខ្ញុំសូមប្រកាសបើកកម្មវិធី «**សង្គម-វប្បធម៌**» ជាផ្លូវការ ហើយសូមអញ្ជើញលោកអ្នកទាំងអស់គ្នា លើកកែវឡើង ដើម្បីអបអរសាទរនូវជោគជ័យរបស់យើងទាំងអស់គ្នា រួមទាំងអបអរដល់កិច្ចប្រជុំ «**ការត្រួតពិនិត្យឡើងវិញជាសកល-លើកទី ៧ ស្តីពីជំនួយសម្រាប់ពាណិជ្ជកម្ម**» និងការ-សម្ពោធដាក់ឱ្យប្រើប្រាស់ «**យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ ២០១៩-២០២៣**» ។ ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី សមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ : អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរគុណ !***